# បញ្ហាពីរយ៉ាង

បញ្ហាពីរយ៉ាង ពាក់ព័ន្ធនឹងលោក សម រង្ស៊ី ដែលរបបនៅភ្នំពេញមិនចង់ជួបប្រទះគឺៈ មាតុភូមិនិវត្ត និង ចាប់ដាក់ពន្ធនាគារ។ បញ្ហាទាំងពីរនេះ វាមានពាក់ព័ន្ធ ដោយចំពោះជាមួយនឹង អ.ស.ប., សហគមអឺរ៉ុប, សហរដ្ឋអាមេរិក និង ប្រទេសប្រជាធិបតេយ្យសេរីមួយចំនួន ដែលគេ មិនអាចស្ថិតនៅព្រងើយកន្តើយទៀតទេ ចំពោះ ការរំលោភ សិទ្ធិមនុស្ស និង បំពានកិច្ចព្រមព្រៀងសន្តិភាពថ្ងៃទី២៣ តុលា ឆ្នាំ ១៩៩១ ពីសំណាក់ របបដឹកនាំសព្វថ្ងៃនៅកម្ពុជា។ ទំនាល់គឺ នៅលើចំណុច ដែលរបបនៅភ្នំពេញនឹងអាច ទទួលទណ្ឌកម្មអន្តរជាតិ។ របបនេះ គ្មានភាពស្របច្បាប់ រួចទៅហើយក្រោយពីការបោះឆ្នោតក្លែងក្លាយនៅឆ្នាំ ២០១៨, ក៏ប៉ុន្តែ អង្គការសហប្រជាជាតិ តាមរយៈអ្នកតំណាង[1] ក្នុងវិស័យសិទ្ធិមនុស្សនៅកម្ពុជា ដែលទទួល អាណត្តិពេញច្បាប់ពីកិច្ចព្រមព្រៀងសន្តិភាព ២៣ តុលា តែងតែធ្វើអនុសាសន៍ ឱ្យរបបនៅភ្នំពេញ តម្រង់ឡើងវិញ គ្រប់សកម្មភាពអវិជ្ជមានរបស់ខ្លួន តែរបបនេះ មិនត្រឹមតែមិនកែ ផ្ទុយទៅវិញ មានតែធ្វើបន្ថែមទៀត ដែលនាំឱ្យខ្លួនជួបប្រទះនឹង បញ្ហាទាំងពីរនេះ ហើយនាំឱ្យ នយៈជីវិត[2]ពេញសិទ្ធិរបស់លោក រង្ស៊ី រស់ឡើងវិញ ទាំងនៅក្នុងស្រុកខ្មែរ និង លើឆាកអន្តរជាតិ។ ទោះបីរបបនៅភ្នំពេញ ទុកលោក រង្ស៊ី ជាទណ្ឌិត តែតុលាការនៅស្រុកខ្មែរ វាគ្មានតម្លៃអ្វីនៅក្នុងចិត្ត នៃប្រជាពលរដ្ឋខ្មែរ និង លើឆាកអន្តរជាតិនោះឡើយ ព្រោះជាអ្នកបំរើដាច់ថ្លៃ នៃបននៅភ្នំពេញ។ ដូច្នេះ ចាប់ សម រង្ស៊ី ដាក់ពន្ធនាគារក្តី និង ខាឃាំងមិនឱ្យវិលត្រឡប់ចូលស្រុកក្តី វារិតតែបន្ថែមកំហុសក្នុងទ្រនូលអសីលធម៌តែប៉ុណ្ណោះ៕

[1] ត្រូវដឹងថា អាណត្តិពេញច្បាប់របស់អ្នកតំណាង អ.ស.ប. នេះ ក៏វាបញ្ជាក់អំពី សភាពជាធរមាននៅឡើយ នៃកិច្ចព្រមព្រៀងសន្តិភាពនៅកម្ពុជា ដែលរបបនៅភ្នំពេញតែងតែបដិសេធ។

[2] វាក្យសព្ទ « រយៈ » យើងប្រើជាគុណនាមរបស់ពាក្យ នយោបាយ។